# ភ្នំបូកគោ **A1, A2 & A3**



| | | |
|---|---|---|
| **ខេត្ត** | : | កំពត ក្រុងព្រះសីហនុ និង កោះកុង |
| **ស្រុក** | : | កំពត ព្រៃនប់ និង កំពង់សិលា |
| **ផ្ទៃដី ( ហិកតា)** | : | ១០១.៥៨៧ |
| **រយៈកំពស់ ( ម៉ែត្រ)** | : | ៩ ដល់ ១.៣២៥ |
| **កូអរដោនេចំណុចកណ្ដាល** | : | ១០$^{0}$៥១ ' ជ ១០៤$^{0}$ ០២ ' ក |

### ការពិពណ៌នាទីកន្លែង

តំបន់ IBA នេះ ស្ថិតក្នុងឧទ្យានជាតិបូកគោ និង ជួរភ្នំដំរី ដែលលាតសន្ធឹងនៅតាមបណ្ដោយផ្លូវជាតិលេខ៤ និង តំបន់ឆ្នេរសមុទ្រប៉ែកខាងត្បូងនៃប្រទេសកម្ពុជា ។ តាមលក្ខណៈសណ្ឋានដី តំបន់ឧទ្យានជាតិនេះត្រូវបានគ្របដណ្ដប់ដោយខ្ពង់រាបជាច្រើន ដែលមានរយៈកំពស់ប្រហែល១.០០០ម៉ែត្រធៀបទៅនឹងនីវ៉ូសមុទ្រ ។ តំបន់សត្វស្លាបសំខាន់ៗនេះរួមមានផ្នែកជាច្រើននៃឧទ្យានជាតិដែលគ្របដណ្ដប់ដោយព្រៃពាក់កណ្ដាលស្រោង និង ព្រៃស្រោង ចាប់ពីរយៈកំពស់៤០០ម៉ែត្រធៀបនឹងនីវ៉ូសមុទ្រ ដែលគេគិតថា ជារយៈកំពស់មួយទាបជាងរយៈកំពស់របស់ក្រួចសំពៅ និង តំបន់ស្ទឹងទឹកឈូ ដែលមានវត្តមានប្រភេទអកត្រីតូច ។ រុក្ខជាតិដុះលើខ្ពង់រាបគ្របដណ្ដប់ដោយព្រៃស្រោងទាបៗលាយឡំជាមួយតំបន់ព្រៃដែលត្រូវបានគេកាប់ឆ្ការ ហើយដុះជំនួសវិញដោយស្មៅ និង មានតំបន់ដីសើមសិប្បនិម្មិតជាច្រើនកន្លែង ។ ខ្ពង់រាបនេះមានចំណោតចោត រីឯភ្នំតូចៗ និង កំពូលរបស់វាគ្របដណ្ដប់ដោយព្រៃពាក់កណ្ដាលស្រោង ។ ស្ទឹងទឹកឈូហូរចាក់ទៅទិសនិរតី ហើយបន្ទាប់មកហូរចូលទៅក្នុងសមុទ្រនៃខេត្តកំពត និង នៅមានព្រែក និង អូរតូចៗជាច្រើនផ្សេងទៀតហូរកាត់ខ្វាត់ខ្វែងនៅក្នុងតំបន់នេះទាំងមូល ។

តំបន់ IBA បានទ្រទ្រង់ប្រភេទក្រួចសំពៅដែលជាប្រភេទមួយក្នុងចំណោមពីរប្រភេទដែលត្រូវបានរកឃើញនៅតាមតំបន់ជួរភ្នំប្រទេសកម្ពុជា-ថៃ ។ លើសពីនេះទៀត មានការកត់ត្រាមួយជាប្រវត្តិសាស្ត្រជាយូរមកហើយនៃប្រភេទចេកទុំប្រាក់ (Silver Oriole *Oriolus mellianus*) នៅក្នុងឆ្នាំ ១៩២៧ ដែលបានបន្សល់ទុកជាកំណត់ត្រាសម្រាប់ប្រទេសកម្ពុជានៃប្រភេទរងគ្រោះនេះ ។ ទោះជាយ៉ាងណាក៏ដោយ ប្រភេទនេះនៅតែមាននៅក្នុងតំបន់ IBA ជាប្រភេទបន្លាស់ទីតែមិនបានបង្កាត់ពូជនៅទីនោះឡើយ ។

### ប្រភេទសត្វស្លាបសំខាន់ៗ

| **ឈ្មោះខ្មែរ** | **ឈ្មោះអង់គ្លេស** | **ឈ្មោះវិទ្យាសាស្ត្រ** | **លក្ខណៈវិនិច្ឆ័យIBA** | |
|---|---|---|---|---|
| កេងកងធំ | Great Hornbill | *Buceros bicornis* | A1 | |
| ក្ងោក | Green Peafowl | *Pavo muticus* | A1 | |
| ក្រួចសំពៅ ឬ មាន់ក្រិច | Chestnut-headed Partridge | *Arborophila cambodiana* | A1 | A2 |
| អកត្រីតូច | Lesser Fish-eagle | *Ichthyophaga humilis* | A1 | |

### ប្រភេទសត្វប្រមូលផ្តុំក្នុងតំបន់មួយជាក់លាក់

មានសត្វស្លាបប្រាំមួយប្រភេទរស់នៅក្នុងប្រភេទព្រៃតំបន់ភ្នំខ្ពស់ៗ ១២ប្រភេទរស់នៅក្នុងប្រភេទព្រៃស្រោង និង មួយប្រភេទរស់ក្នុងប្រភេទព្រៃរបោះ (សូមមើលតារាងឧបសម្ព័ន្ធ៤) ។

### ប្រភេទពានរជាតិទទួលរងការគំរាមកំហែងពិភពលោក

ទោចម្កុដ ស្វាត្រោស រញ្ជីប្រផេះ ។

### ដរី និង ពពួកក្រចកជំពាមទទួលរងការគំរាមកំហែងពិភពលោក

ដំរី ខ្ទីង និង កែះ ។

### ការគំរាមកំហែងលើជីវៈចំរុះ

ព្រៃឈើជាច្រើននៅក្នុងតំបន់ IBA ត្រូវបានកាប់ផ្តួលរំលំ ហើយក៏មានការកាប់ឫស្សី និង អនុផលព្រៃឈើផ្សេងៗទៀតផងដែរ ។ ការកាប់បំផ្លាញព្រៃឈើខុសច្បាប់ត្រូវបានគេប៉ាន់ប្រមាណថា មានឥទ្ធិពលលើឧទ្យានជាតិបូកគោប្រមាណ៨០% ។ ការថយចុះ និង ការបាត់បង់ទីជំរកគឺជាការគំរាមកំហែងមួយយ៉ាងធ្ងន់ធ្ងរលើជីវៈចំរុះនៅក្នុងតំបន់ IBA នេះគួបផ្សំនឹងប្រជាពលរដ្ឋមូលដ្ឋានកាប់ឆ្ការព្រៃសម្រាប់ដីកសិកម្ម ។ ការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរមួយផ្សេងទៀតនោះគឺការប្រមាញ់ដោយមានការប្រើប្រាស់អន្ទាក់យ៉ាងច្រើន ។ ប្រភេទសត្វស្លាប ដូចជាក្រួចសំពៅ ក្ងោក ពពួកកេងកងត្រូវបានឃើញគេតាំងលក់នៅតាមបណ្តោយផ្លូវជាតិលេខ៤ ។ ទោះជាយ៉ាងក៏ដោយ ក៏សកម្មភាពនៃការអនុវត្តន៍ច្បាប់ក្នុងគោលបំណងកាត់បន្ថយ ឬ លុបបំបាត់ការបរបាញ់ត្រូវបានធ្វើឡើង ដោយទទួលបានជោគជ័យគួរឱ្យកត់សំគាល់នាពេលថ្មីៗនេះ ។

### អនុសាសន៍

សកម្មភាពនៃការអនុវត្តន៍ច្បាប់ និង ការល្បាតរបស់សត្តរក្សដែលកំពុងមាននៅពេលបច្ចុប្បន្ននៅក្នុងឧទ្យានជាតិបូកគោបានផ្តោតលើការយកចិត្តទុកដាក់ចំពោះសកម្មភាពល្មើសច្បាប់ទាំងឡាយដូចជា ការបរបាញ់ និង ការកាប់បំផ្លាញព្រៃឈើគួរតែត្រូវបន្ត និង ពង្រីកសកម្មភាពនេះឱ្យបានគ្របដណ្តប់លើតំបន់សំខាន់ៗ ។

### ឯកសារយោង


Akers, P. (2000) *Bird surveys in Cambodia January-March 2000*. Unpublished sabbatical report to RSPB.

BirdLife International (2001) *Threatened birds of Asia: the BirdLife International Red Data Book*. Cambridge, U.K: BirdLife International.

Delacour, J. (1929) On the birds collected during the fourth French expedition to French Indochina. *Ibis* 12 (5): 193-220.

Delacour, J. and Jabouille, P. (1928) Twenty-one new birds from Indo-China. *Bull. Brit. Orn. Club* 48: 125-136

Delacour, J., and Jabouille, P. (1931) *Les Oiseaux de l'Indochine Francaise*. vols I-IV. Paris: Exposition Coloniale Internationale. (In French.)

Engelbach, P. (1936) Notes de la région de Kampot (Cambodge). *L'Oiseau et la Revue Francaise d'Ornithologie*. 6: 347-348. (In French.)

Engelbach, P. (1938) Note sur quelques oiseaux du Cambodge. *L'Oiseau et la Revue Francaise d'Ornithologie*. 8: 384-394. (In French.)

Engelbach, P. (1948) Liste complémentaire aux oiseaux du Cambodge. *L'Oiseau et la Revue Francaise d'Orni thologie.* 18: 5-26. (In French.)

Goes, F. Tan Setha and Ros Bansok (1998) *Preliminary bird survey for cluster of three national parks in southern C ambodia.* Phnom Penh: European Commission Support Programme to the Environment Sector in C ambodia.

Goes, F. and Davidson, P. eds. (2002) Recent sightings. *Cambodia Bird News* 9: 47-59.

Net Neath and Tan Setha eds. (2001) A wildlife survey of Bokor National Park, Cambodia. Phnom Penh: Wildlife C onservation Society.

Poole, C. M. (1999) Little known oriental bird: Chestnut-headed Partridge *Arborophila cambodiana*. *Bull. Oriental Bird Club* 30: 46-50.

Tan Setha and Pech Bunnat (2000) *Threatened galliformes of Cambodia.* Paper presented at the International Galliformes Symposium, Kathmandu, Nepal, September 2000.

Tan Setha and Pech Bunnat (2001) Recent information on the status and conservation of galliformes in Cambodia. Pp. 39-44 in P. McGowan ed. *Galliformes 2000: Proceedings of the 2nd International Galliformes Symposi um*. Reading: World Pheasant Association.

Thomas, W.W. 1964. *A preliminary list of the birds of Cambodia*. Unpubl.